ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និងឧតុនិយម

លេខ ១៧៧ ៥៥៣ ធទឧ

# សេចក្ដីជូនដំណឹង

ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដល់សាធារណជនឱ្យបានជ្រាបថា បន្ទាប់ពីបានធ្វើការសង្កេត និងតាមដានលើស្ថានភាពធាតុអាកាសរួចមក ឃើញថា នៅវេលាម៉ោង 13 h 00 រសៀល ថ្ងៃទី 21 ខែមិថុនា ឆ្នាំ 2011 មានព្យុះមួយឈ្មោះ **ហៃម៉ា** បានកើតនៅសមុទ្រចិនខាងត្បូង ត្រង់ចំណុចខ្សែស្របទី 19 អង្សា 7 នៃរយៈទទឹងខាងជើង និងខ្សែវណ្ណទី 116 អង្សា នៃរយៈបណ្ដោយខាងកើត និងកំពុងធ្វើដំណើរឆ្ពោះទៅភាគខាងជើង នៃកោះហៃណាំ ក្នុងល្បឿន 15 km/h ។ ព្យុះនេះនឹងមានឥទ្ធិពលមកលើព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី 22 ដល់ថ្ងៃទី 24 ខែមិថុនា ឆ្នាំ 2011 ពិសេសនៅតំបន់មាត់សមុទ្រ តំបន់ខ្ពង់រាបភាគខាងជើង និងតំបន់ខ្ពង់រាបភាគឦសាន ។ ស្ថានភាពអាកាសធាតុបែបនេះ នឹងបង្កឱ្យ :

- **តំបន់ខ្ពង់រាបភាគខាងជើង និងតំបន់ខ្ពង់រាបភាគឦសាន** : មានភ្លៀងធ្លាក់ច្រើន និងអាចបង្កឱ្យមានជំនន់ទឹកភ្លៀងនៅខេត្តមួយចំនួន ដូចជា : ព្រះវិហារ ឧត្តរមានជ័យ ក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី ។
- **តំបន់មាត់សមុទ្រ** : មានភ្លៀងធ្លាក់ច្រើន និងមានខ្យល់បក់បោកខ្លាំង នៅខេត្តកោះកុង ព្រះសីហនុ កែប និងខេត្តកំពត ។ ឯរលកសមុទ្រ មានកំពស់ ពី 1-2 ម៉ែត្រ ។
- **តំបន់ទំនាបកណ្ដាល** : មានភ្លៀងធ្លាក់ក្នុងកម្រិតមធ្យម ។

ឥទ្ធិពលនៃព្យុះនេះ ក៏នឹងធ្វើឱ្យកំពស់ទឹកទន្លេមេគង្គហក់ឡើងផងដែរ ។

យោងតាមសភាពការណ៍ធាតុអាកាសខាងលើ ក្រសួងធនធានទឹក និងឧតុនិយម សូមជម្រាបជូនដំណឹងដល់អាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលរស់នៅតាមដងទន្លេមេគង្គ និងតាមបណ្ដាខេត្តដូចបានជម្រាបជូនខាងលើ សូម **បង្កើនការយកចិត្តទុកដាក់ប្រុងប្រយ័ត្ន** ដើម្បីចៀសវាងនូវគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១

រដ្ឋមន្ត្រី

លឹម គានហោ

អគារលេខ ៤៧ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារលេខ (៨៥៥ ២៣.៧២៥ ៩៨៩ / (៨៥៥ ២៣.៤២៦ ៣៤៥
# 47 Preah Norodom B V D. Phnom Penh, Fax/Phone: ( 855) 23.725 989 / ( 855 ) 23.426 345 E-mail : mowram@cambodia.gov.kh